# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២
# និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់មន្ទីរអភិវឌ្ឍន៍ជនបទ
# ខេត្តកំពង់ធំ

## សេចក្តីផ្តើម

ការអភិវឌ្ឍជនបទ ជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋជនបទ។ ក្រោមការចង្អុលបង្ហាញរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ប្រកាន់ភ្ជាប់នូវតួនាទី និងភារកិច្ចដែលក្រសួងបានប្រគល់ឲ្យ សមិទ្ធផលធំៗដែលមន្ទីរសម្រេចបានគឺ ផ្លូវជនបទ ស្ពាន លូរំដោះទឹក សំណង់សិល្បការ ប្រព័ន្ធធារាសាស្រ្តខ្នាតតូច អណ្តូងទឹកស្អាត បង្គន់អនាម័យ ពាងត្រងទឹកភ្លៀងគ្រួសារ និងតាមទីសាធារណៈជាដើម ជូនប្រជាពលរដ្ឋក្នុងខេត្តកំពង់ធំ។ ក្រៅពីនេះប្រជាពលរដ្ឋក៏ទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីបង្កើតមុខរបររកប្រាក់ចំណូលក្នុងគ្រួសារ ធ្វើឲ្យស្ថានភាពក្រីក្របន្តធ្លាក់ចុះដូចការព្យាករណ៍របស់រាជរដ្ឋាភិបាលប្រមាណ ១% ក្នុង១ឆ្នាំ។ ទាំងនេះគឺជាផ្លែផ្កានៃការអនុវត្តយុទ្ធសាស្រ្តចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា។

ខេត្តកំពង់ធំ ជាខេត្តមួយក្នុងចំណោមរាជធានីខេត្តទាំង២៥ មានទីតាំងស្ថិតនៅទិសឧត្តរ នៃរាជធានីភ្នំពេញ ដែលជាចំណុចកណ្តាលនៃប្រទេសកម្ពុជា មានព្រំប្រទល់ខាងជើងទល់នឹងខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង ខាងត្បូងទល់នឹងខេត្តកំពង់ចាមនិងខេត្តកំពង់ឆ្នាំង ខាងកើតជាប់នឹងខេត្តកំពង់ចាម និងខេត្តក្រចេះ ខាងលិចទល់នឹង ខេត្តកំពង់ឆ្នាំង និងខេត្តសៀមរាប។ រដ្ឋបាលដែនដីខេត្តមាន ០៨ ស្រុក ០១ក្រុង មាន ៨១ឃុំសង្កាត់ និងមាន ៧៦៧ភូមិ ផ្ទៃដីសរុប ១៥ ០៦១ គម$^{២}$ ប្រជាជនសរុប ៨៣៩ ៩៩១ នាក់ ស្រី៤២៥ ៨៤៦ នាក់ ស្មើនឹង ១៧៧ ៧២៨ គ្រួសារ ប្រជាជនប្រមាណ៨០ភាគរយជាកសិករ។

## I. សមិទ្ធផលសម្រេចបាន

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

- ការងាររដ្ឋបាល និងបុគ្គលិក បច្ចុប្បន្នមន្ទីរមានមន្ត្រីសរុបចំនួន ៣៤រូប ស្រី ០៦រូប ក្នុងនោះមាន៖
  - ប្រធានមន្ទីរ ០១រូប និងអនុប្រធានមន្ទីរ ០៣រូប
  - មន្ត្រីបម្រើការងារនៅតាមការិយាល័យជំនាញ ទាំង១០ ការិយាល័យចំណុះឲ្យមន្ទីរ សរុបមានចំនួន ៣០ រូប ស្រី ០៦ រូប និងមន្ត្រីកិច្ចសន្យា ០១ រូប
  - បានទទួលលិខិតចូលពីបណ្តាក្រសួង អង្គភាពនានាក្រោមន្ទីរមានៈចំនួន ១១០ លេខ

- បានទទួលលិខិតចូលពីក្រសួង នាយកដ្ឋាននានាក្រោមឱវាទក្រោមឱវាទក្រសួង និងអង្គភាពក្រោមឱវាទមន្ទីរ មានៈ ចំនួន ២៨៨ លេខ
- បានចេញលិខិត សរុប ៦២៣ លេខ
- ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំផ្សព្វផ្សាយ ដល់មន្ត្រីរាជការ
- ការបណ្តុះបណ្តាលដល់មន្ត្រីរាជការក្រោមឱវាទមន្ទីរ គឺជាកត្តាសំខាន់ដែលថ្នាក់ក្រសួង ក៏ដូចជា មន្ទីរត្រូវបង្កើនការលើកទឹកចិត្តដល់បុគ្គលិកមន្ត្រីរាជការឱ្យខិតខំបង្កើនចំណេះដឹង និងមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តដឹកនាំគ្រប់គ្រងគម្រោងកម្មវិធីឱ្យមានប្រសិទ្ធិភាពខ្ពស់
- បញ្ជូនមន្ត្រីរាជការចំនួន ២៦នាក់ ស្ត្រី ០៤នាក់ ចូលរួមក្នុងសិក្ខាសាលា និងបណ្តុះបណ្តាលក្រៅខេត្ត និងក្នុងខេត្ត បានចំនួន ២៣វគ្គ
- បានចូលរួមកិច្ចប្រជុំ និងការងារចាំបាច់ផ្សេងៗក្នុងខេត្តបានចំនួន ១៩០លើក
- ថ្ងៃទី២៥-២៧ ខែតុលា និងថ្ងៃទី ១៥- ២៤ ខែវិច្ឆិកា ឆ្នាំ២០២២ លោកប្រធានមន្ទីរ លោកអនុប្រធានមន្ទីរ និងប្រធានការិយាល័យផ្លូវជនបទ បានចូលរួមកម្មវិធីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្តកំពង់ធំ អណត្តិទី៣ ឆ្នាំ២០២២
- ថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំកិច្ចប្រជុំប្រចាំខែកញ្ញា និងទិសដៅការងារប្រចាំខែតុលា ក្រោមអធិបតីភាព លោក មុំ ចែម ប្រធានមន្ទីរ
- ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំកិច្ចប្រជុំប្រចាំខែសីហា និងទិសដៅការងារប្រចាំខែកញ្ញា ក្រោមអធិបតីភាព លោក មុំ ចែម ប្រធានមន្ទីរ
- ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំកិច្ចប្រជុំប្រចាំខែកក្កដា និងទិសដៅការងារប្រចាំខែសីហា ក្រោមអធិបតីភាព លោក មុំ ចែម ប្រធានមន្ទីរ
- ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២២ បានរៀបចំកិច្ចប្រជុំក្រុមការងារវិស័យទឹកស្អាត ការសម្អាត និងអនាម័យថ្នាក់ខេត្ត (PWG) ប្រចាំឆមាសទី២ ឆ្នាំ២០២២ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម ព្រឹម រដ្ឋា អភិបាលរងខេត្តកំពង់ធំ និងអ្នកចូលរួមសរុប៣២នាក់ ស្រី០៤នាក់
- ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំកិច្ចប្រជុំប្រចាំខែមិថុនា និងទិសដៅការងារប្រចាំខែកក្កដា ក្រោមអធិបតីភាព លោក មុំ ចែម ប្រធានមន្ទីរ
- ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសទឹកស្អាតនិង អនាម័យ(PWG) ថ្នាក់ខេត្ត ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពខេត្តឆ្នាំ២០១៩-២០២៣ ធៀបនឹងគោលដៅឆ្នាំ២០២៣ ឱ្យបាន៩០% ក្រោមអធិបតីភាព ឯ.ឧ ចាន់ តារា និងអ្នកចូលរួម ៣៨នាក់ ស្រី ០៦នាក់
- ថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំកិច្ចប្រជុំប្រចាំខែមីនា និងទិសដៅការងារប្រចាំខែមេសា ក្រោមអធិបតីភាព លោក មុំ ចែម ប្រធានមន្ទីរ

- ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២២ លោក មុំ ចែម ប្រធានមន្ទីរ និងប្រធានការិយាល័យជំនាញទាំង ១០ បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈប្រព័ន្ធអនឡាញ
- ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំកិច្ចប្រជុំប្រចាំខែកុម្ភៈ និងទិសដៅការងារប្រចាំខែមីនា ព្រមទាំងរៀបចំប្រារព្ធខួបទី១១១ ទិវាអន្តរជាតិនារី ០៨ មីនា ក្រោមអធិបតីភាព លោក មុំ ចែម ប្រធានមន្ទីរ
- ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២២ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំកិច្ចប្រជុំប្រចាំខែមករា និងទិសដៅការងារប្រចាំខែកុម្ភៈ ក្រោមអធិបតីភាព លោក មុំ ចែម ប្រធានមន្ទីរ។

- ការងារផែនការ
  - បូកសរុបរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាសទី១, ត្រីមាសទី៣, ឆមាសទី១, ០៩ខែ និងប្រចាំឆ្នាំ២០២២ ជូននាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ និងជូនរដ្ឋបាលខេត្តកំពង់ធំ។
- ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

| ជំពូក | បរិយាយ | ស្ថានភាពឥណទាន គិតជារៀល | បណ្ដាខែមុន | ចំណាយក្នុង ខែ ធ្នូ | ចំណាយបូកយោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ការទិញ | 146,000,000 | 116,777,274 | 7,653,550 | 124,430,824 | 21,569,176 |
| ៦១ | សេវា ខាងក្រៅ | 930,100,000 | 864,664,927 | 59,113,759 | 923,778,686 | 6,321,314 |
| ៦៣ | ពន្ធ និង អាករ | 3,000,000 | 1,600,000 | | 1,600,000 | 1,400,000 |
| ៦៤ | បន្ទុក បុគ្គលិក | 657,000,000 | 595,530,000 | 53,937,500 | 649,467,500 | 7,532,500 |
| សរុបរួម | | **1,736,100,000** | **1,578,572,201** | **120,704,809** | **1,699,277,010** | **36,822,990** |

- ការងារសវនកម្ម និងការងារអធិការកិច្ច
  - ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២២ ប្រតិភូអធិការកិច្ចក្រសួងទំនាក់ទំនងសភា ព្រឹទ្ធសភា និងអធិការកិច្ច ដឹកនាំដោយ លោក ឡុង មុយ ចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី-ភារកិច្ច ការគ្រប់គ្រងសេវាសាធារណៈ ការអនុវត្តកិច្ចលទ្ធកម្ម សាធារណៈ ក្នុងការិយបរិច្ឆេទ២០២១ និងបណ្ដាឆ្នាំពាក់ព័ន្ធ
  - ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ គណៈប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះធ្វើអធិការកិច្ចលើ ការគ្រប់គ្រង ការអនុវត្តចំណូល-ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ ២០២១ និងឆ្នាំពាក់ព័ន្ធ
  - ថ្ងៃទី ០៩-១០ ខែមីនា ឆ្នាំ២០២២ ក្រុមសវនកម្មផ្ទៃក្នុងដឹកនាំដោយ លោក ពេជ្រ សេដ្ឋា នៃក្រសួងអភិវឌ្ឍន៍ជនបទ បានចុះមកត្រួតពិនិត្យលើការងារគ្រប់គ្រងរដ្ឋបាល របាយការណ៍ចំណូលចំណាយ និងឯកសារលទ្ធកម្មឆ្នាំ២០២១ និងបណ្ដាឆ្នាំពាក់ព័ន្ធ
  - ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២២ ប្រតិភូក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានចុះធ្វើអធិការកិច្ច លើការគ្រប់គ្រងការអនុវត្តតួនាទី ភារកិច្ចក្នុងការងារសាង

សង់ ជួសជុលថែទាំប្រព័ន្ធទឹកស្អាត និងការសាងសង់ ជួសជុលផ្លូវ ថែទាំខួប ប្រចាំ និង បន្ទាន់ ក្នុងការិយបរិច្ឆេទ ២០២០ និងបណ្តាឆ្នាំពាក់ព័ន្ធ និងត្រួតពិនិត្យនូវវិធានការរបស់ គណៈប្រតិភូអធិការកិច្ច ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុង ការិយបរិច្ឆេទ ២០១៨។

- ការងារយេនឌ័រ
  - ចូលរួមកិច្ចប្រជុំស្តីពីការបញ្ជ្រាបយេនឌ័រ ប្រចាំត្រីមាសទី៣ នៅសាលប្រជុំមន្ទីរកិច្ចការនារី ខេត្តកំពង់ធំ
  - ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម នៅមន្ទីរ កិច្ចការនារី
  - ចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុ និងសេវាឥណទាន សមស្រប និងយេនឌ័រលើកទី៤ ដែលរៀបចំដោយមន្ទីរកិច្ចការនារីខេត្តកំពង់ធំ
  - ថ្ងៃទី ១៥-១៧ ខែមិថុនា ឆ្នាំ ២០២២ ក្រុមការងារយេនឌ័រមន្ទីរ បានចូលរួមកិច្ចប្រជុំ បច្ចេកទេសសម្រាប់វគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុ សេវាឥណទានសមស្រប និងយេនឌ័រលើកទី៤ នៅសាលប្រជុំមន្ទីរកិច្ចការនារីខេត្ត
  - ថ្ងៃទី ១៧-១៨ ខែឧសភា ឆ្នាំ ២០២២ ចូលរួមកិច្ចប្រជុំបច្ចេកទេសសម្រាប់វគ្គបណ្តុះបណ្តា ល ស្តីពី ស្ត្រី និងបដិសណ្ឋារកិច្ចក្នុងវិស័យទេសចរណ៍ និងរបៀបប្រើប្រាស់ Tablet រួមទាំង ការថតរូប នៅសាលប្រជុំមន្ទីរកិច្ចការនារីខេត្ត
  - ចូលរួមកិច្ចប្រជុំបច្ចេកទេសសម្រាប់វគ្គបណ្តុះបណ្តាលស្តីពី ស៥ ការវេចខ្ចប់ និងកិច្ចសន្យា ទិញ-លក់ ដែលរៀបចំដោយមន្ទីរកិច្ចការនារីខេត្ត
  - ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកត់ត្រាចំណូល-ចំណាយការងារយេនឌ័រលើកទី២ នៅ ភូមិព្រៃគុយ ឃុំព្រៃគុយ ស្រុកកំពង់ស្វាយ(សហគមន៍ដាំបន្លែ)និងភូមិអូរគ្រូកែ ឃុំសំបូរណ៌ ស្រុកប្រាសាទសំបូរ (សហគមន៍សិប្បកម្ម)ដើម្បីបង្កើនភាពអង់អាច ផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (WEE)
  - ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ផែនការអាជីវកម្ម និងសហគមន៍សន្សំប្រាក់ នៅភូមិអូរ គ្រូកែ ឃុំសំបូរណ៌ ស្រុកប្រាសាទសំបូរ ដោយក្រុមការងារបង្កើនភាពអង់អាចផ្នែក សេដ្ឋកិច្ចដល់ ស្ត្រី គាំទ្រដោយ អង្គការ JICA និងមន្ទីរកិច្ចការនារី។

**២.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

- ការងាររៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ
  - ចុះស្រង់ទិន្នន័យ និងធ្វើបច្ចុប្បន្នភាពផ្លូវជនបទ បានចំនួន៤៧ខ្សែ ប្រវែង ៣១០ ៦០០គ.ម ស្ថិតក្នុងស្រុកស្ទោង ស្រុកសណ្តាន់ ស្រុកបារាយណ៍ស្រុក តាំងគោក ស្រុកសន្ទុក ស្រុក ប្រាសាទសំបូរ ស្រុកប្រាសាទបល្ល័ង្គ ស្រុកកំពង់ស្វាយ ក្រុងស្ទឹងសែន
  - បានដាំកូនឈើតាមដងផ្លូវប្រភេទឈើធ្នង់, បេង, ស្វាយ បានចំនួន ៥៤០ដើម និងគ្រាប់ ត្នោតចំនួន ៨០០គ្រាប់ ស្ថិតក្នុងស្រុកប្រាសាទសំបូរ និងស្រុកកំពង់ស្វាយ
- ការងាររាប់ចំនួនចរាចរណ៍

- ចុះរាប់ចរាចរណ៍ចំនួនយានយន្ត ផ្លូវ០៥ខ្សែ ប្រវែង ១៧២.១០០ គ.ម ស្ថិតក្នុងស្រុកស្ទោង ស្រុកសណ្ដាន់ ស្រុកបារាយណ៍ស្រុកតាំងគោក ស្រុកសន្ទុក ស្រុកប្រាសាទ សំបូរ ស្រុកប្រាសាទបល្ល័ង្គ ស្រុកកំពង់ស្វាយ ក្រុងស្ទឹងសែន

- ការងារសាងសង់ទីទួលសុវត្ថិភាព
  - បានសាងសង់ទីទួលសុវត្ថិភាពចំនួន ០១កន្លែង ស្ថិតនៅភូមិរការ សង្កាត់ស្រយ៉ូវ ស្ទឹងសែន។
- ការងារថែទាំផ្លូវជនបទ និងសំណង់សិល្បការ្យ
  - បានអនុវត្តគម្រោងផ្លូវថែទាំជាប្រចាំ ចំនួន ១៣ ខ្សែ ប្រវែងសរុប ១២០ ៩៥០ ម៉ែត្រ ស្ថិតក្នុងស្រុកបារាយណ៍ ស្រុកកំពង់ស្វាយ ស្រុកប្រាសាទបល្ល័ង្គ ស្រុកសន្ទុក និងស្រុកប្រាសាទសំបូរ សម្រេច ១០០%បានអនុវត្តគម្រោងផ្លូវថែទាំជាលក្ខណៈខួប ចំនួន ០២ ខ្សែ ប្រវែងសរុប ១២ ៧០០ ម៉ែត្រ ស្ថិតក្នុង ឃុំតាំងក្រសាំង ឃុំទីពោ ស្រុកសន្ទុក សម្រេច ១០០%។
- ការងារជួសជុលផ្លូវជនបទ និងសំណង់សិល្បការ្យ
  - បានអនុវត្តគម្រោងផ្លូវជួសជុលបន្ទាន់ ចំនួន ០១ ខ្សែ ប្រវែងសរុប ១ ០០០ ម៉ែត្រ ស្ថិតក្នុងឃុំទីពោ ស្រុកសន្ទុក សម្រេចបាន ១០០% ។

**៣. ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

- សាងសង់បង្គន់អនាម័យ/បដិភាគសម្ភារៈអនាម័យ ០១ឃុំ ចំនួន ១៨បង្គន់ ស្ថិតក្នុងស្រុកស្ទោង (ថវិកាមន្ទីរ)
- បានសាងសង់អណ្ដូងស្នប់អាហ្វ្រីដេវ ចំនួន១៣អណ្ដូងភូមិដងក្ដារ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ (ថវិកានាយកដ្ឋាន)

**៤. ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- ការងារលើកកម្ពស់កំណើនសេដ្ឋកិច្ចគ្រួសារនៅជនបទ
  - បានចុះផ្សព្វផ្សាយ និងបង្កើនឥណទានជនបទ នៅឃុំស្រើង ស្រុកប្រាសាទសំបូរ ដែលមានអ្នកចូលរួមសរុប ១១នាក់ ស្រី០៤នាក់។
- ការងារអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច
  - ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី២៨ និងលើកទី១៨ នៅកម្ពុជា ក្រោមប្រធានបទ "តួនាទីស្ត្រីជនជាតិដើមភាគតិច ក្នុងការអភិរក្ស និងការផ្ទេរចំណេះដឹងប្រពៃណី" ស្ថិតនៅវត្តសេរីកើតបុណ្យ ក្នុងស្រុកប្រាសាទសំបូរ ដែលមានអ្នកចូលរួមសរុប ២១០នាក់ ស្រី ៨៦នាក់
  - បានចុះធ្វើបច្ចុប្បន្នភាពសហគមន៍ជនជាតិភាគតិច នៅស្រុកសណ្ដាន់ ភូមិស្វាយ មានចំនួនប្រជាជនសរុប ៤៧ នាក់ ស្រី ៣១នាក់ ស្មើនឹង ០៩គ្រួសារ, ភូមិវាលព្រីងលើ មានចំនួនប្រជាជនសរុប ២៦ នាក់ ស្រី ១៤នាក់ ស្មើនឹង ០៦គ្រួសារ និងស្រុកប្រាសាទបល្ល័ង្គ ភូមិម្រាក ខ មានចំនួនប្រជាជនសរុប ៧១៨ នាក់ ស្រី ៣៦០នាក់ ស្មើនឹង ១៥៩គ្រួសារ, ភូមិខ្នាក់ មានចំនួនប្រជាជនសរុប ២៦៦ នាក់ ស្រី ១៣១នាក់ ស្មើនឹង ៥២គ្រួសារ

- បានចុះស្រង់ទិន្នន័យដីធ្លី របស់សហគមន៍ជនជាតិដើមភាគតិច នៅភូមិងន ស្រុកសណ្ដាន់ មានផ្ទៃដីសរុប ៦០០,៥១ ហិកតា និងថ្នល់បែក ស្រុកកំពង់ស្វាយ មានផ្ទៃដីសរុប ១១,៦៤ ហិកតា
- បានចុះស្រង់ទិន្នន័យដីធ្លី របស់សហគមន៍ជនជាតិដើមភាគតិច នៅភូមិច្រម៉ាស់ ស្រុកប្រាសាទសំបូរ មានផ្ទៃដី សរុប ៤៣២ ហិកតា និងភូមិខ្មែរ ស្រុកសណ្ដាន់មានផ្ទៃដី សរុប ៥០,៩០ហិកតា
- បានចុះស្រង់ទិន្នន័យដីធ្លី របស់សហគមន៍ជនជាតិដើមភាគតិច នៅភូមិវាលវែង ស្រុកប្រាសាទសំបូរ មានផ្ទៃដី សរុប ៣ ០០០ ហិកតា និងភូមិក្រាំងដើម ស្រុកសណ្ដាន់ មានផ្ទៃដី សរុប ៦,២៥ ហិកតា
- បានចុះស្រង់ទិន្នន័យដីធ្លី របស់សហគមន៍ជនជាតិដើមភាគតិច នៅភូមិដងទទឹង ឃុំងន ស្រុកសណ្ដាន់ មានផ្ទៃដី សរុប ៤៥,៩៥ ហិកតា និងភូមិកាល់មេយ ឃុំត្បូងក្រពើ ស្រុកសន្ទុក មានផ្ទៃដី សរុប ១៧ ហិកតា
- បានចុះស្រង់ទិន្នន័យដីធ្លី របស់សហគមន៍ជនជាតិដើមភាគតិច នៅភូមិស្វាយ មានផ្ទៃដី សរុប ១៧,៤៥ ហិកតា និងភូមិវាលព្រីងលើ មានផ្ទៃដី សរុប ២៧,០៥ ហិកតា ស្ថិតនៅឃុំងន ស្រុកសណ្ដាន់។

## ៥. សមិទ្ធិផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ

### ៥.១. គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យជនបទទី៣ (មន្ត្រីចំនួន ០៧នាក់)

អនុវត្តនៅឃុំឈូកខ្សាច់ ឃុំចើងដើង ស្រុកបារាយណ៍ និងឃុំទីពោ ស្រុកសន្ទុក មានដូចតទៅៈ

- ពាងត្រងទឹកភ្លៀងចំនួន ៥ ៥៧០ សម្រេចបាន ៥ ៥៧០ ពាង
- ប្រព័ន្ធចែកចាយទឹកចំនួន០២កន្លែង សម្រេចបាន ១០០%
- អណ្តូងខួងជ្រៅ ២២៣ សម្រេចបាន ១០០%
- អាងត្រងទឹកភ្លៀងចំនួន ០៣ សម្រេចបាន ១០០%
- បង្គន់សាធារណៈចំនួន ០៦ សម្រេចបាន ១០០%
- បង្គន់អនាម័យតាមផ្ទះចំនួន ១ ១៥៧ សម្រេចបាន ១ ១៣៥ បង្គន់។

អនុវត្តនៅឃុំចុងដូង ឃុំត្នោតជុំ ស្រុកបារាយណ៍ មានដូចតទៅៈ

- អណ្តូងខួងជ្រៅ ៥៩ សម្រេចបាន ១០០%
- ពាងត្រងទឹកភ្លៀងចំនួន ១ ៣៨៩ សម្រេចបាន ៦៥៥ ពាង។

### ៥.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ (មន្ត្រីចំនួន០៤នាក់ )

- គម្រោងសំណង់ស៊ីវិល (ផ្លូវក្រាលគ្រួសក្រហម) ចំនួន ៥៣ខ្សែ ប្រវែង ៧១,៣៦០ គ.ម សម្រេចបាន ១០០%។

### ៥.៣. គម្រោងគាំទ្រនិរន្តរភាពហេដ្ឋារចនាសម្ព័ន្ធដើម្បីទីផ្សារកសិករ និងពាណិជ្ជូបនីយកម្ម (SAAMBAT) (មន្ត្រីចំនួន០៣នាក់)

- បានចូលរួមសិក្ខាសាលាស្តីពីការជ្រើសរើស និងការកំណត់អាទិភាពតំបន់ប៉ូល សេដ្ឋកិច្ច ចំនួន ១៦ សម្រាប់ដំណាក់កាលទី១
- បានរៀបចំការប្រជុំពិភាក្សា ការកំណត់តំបន់ស្នូលនៃប៉ូលសេដ្ឋកិច្ចចំនួន២ និងវិភាគពីតម្រូវការហេដ្ឋារចនាសម្ព័ន្ធជនបទសម្រាប់អនុវត្តគម្រោងSAAMBAT នៅសាលប្រជុំនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ ក្រោមអធិបតីភាព លោក ប្លង់ សាឡួន ជាប្រធានគ្រប់គ្រងគម្រោង និងជាប្រធានអង្គប្រជុំ
- បានរៀបចំធ្វើបញ្ជីស្នើសុំ ពីតម្រូវការហេដ្ឋារចនាសម្ព័ន្ធជនបទ សម្រាប់អនុវត្តគម្រោង
- បានចុះប្រមូលពត៌មានផ្សេងៗនៃតំបន់ស្នូល នៅក្នុងស្រុកស្ទោង និងក្នុងស្រុកកំពង់ស្វាយ។

**៥.៤. មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន** (មន្ត្រីចំនួន០៥នាក់)

- វគ្គបណ្តុះបណ្តាលនៅតាមមូលដ្ឋាន ស្ថិតនៅ ស្រុកប្រាសាទបល្ល័ង្គ និងស្រុកកំពង់ស្វាយៈ

| ល.រ | ឈ្មោះវគ្គ | កាលបរិច្ឆេទ | ចំនួនសិក្ខាកាម | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ចំនួនវគ្គ | ចំនួនសរុប | ស្រី | |
| ១ | បច្ចេកទេសចិញ្ចឹមមាន់លក្ខណៈគ្រួសារ | ២៤-២៦/១០/២២ | ០១ | ៣៥ | ៣៣ | |
| ២ | ការផលិតសាប៊ូលាងចាន | ១៧-២០/១០/២២ | ០១ | ១៥ | ១៤ | |
| ៣ | ជួសជុល និងថែទាំគ្រឿងយន្តកសិកម្ម | ០៦-១០/០៦/២២ | ០១ | ១៥ | ០ | |
| ៤ | ជួសជុល និងថែទាំគ្រឿងយន្តកសិកម្ម | ១៨-២២/០៧/២២ | ០១ | ១៥ | ០ | |
| សរុប | | | **០៤** | **៨០** | **៤៧** | |

**៥.៥. គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ** (មន្ត្រីចំនួន០៣នាក់)

បានអនុវត្តសកម្មភាពនៅភូមិបញ្ញាជី ឃុំត្បូងក្រពើ ស្រុកសន្ទុកៈ

- ឥណទានទោល
  - មានអតិថិជនខ្ចី ០១នាក់ ជាប្រុស ទឹកប្រាក់ចំនួន ៦.០០០.០០០ រៀល
- ឥណទានក្រុមជានា
  - មានអតិថិជនខ្ចី ១៦ នាក់ ជាស្រី ១៦នាក់ ចែកចេញជា០៥ក្រុមអតិថិជនក្នុងមួយក្រុមមានសមាជិកពី០៣នាក់ ទៅ ០៤នាក់ អតិថិជនមួយនាក់ខ្ចី ១.០០០.០០០ រៀល រយៈពេលខ្ចី ១០ខែ
  - ទឹកប្រាក់ក្នុងដៃអតិថិជនមាន **១៩.១០០.០០០ រៀល**

**តារាងរបាយការណ៍ឥណទានសង្ខេបប្រចាំខែ ធ្នូ ឆ្នាំ ២០២២**

| ល.រ | ខេត្ត | ឥណទានក្នុងដៃអតិថិជន (រៀល) | ចំនួនក្រុម | ចំនួនអ្នកខ្ចី | ចំនួនស្រី | ចំនួនភូមិ | ចំនួនឃុំ | ចំនួនស្រុក |
|---|---|---|---|---|---|---|---|---|
| ១-ឥណទានទោល | | | | | | | | |
| ក | កំពង់ធំ | 12,000,000 | 0 | 0 | | 0 | 1 | 1 |
| សរុប | | 12,000,000 | 0 | 0 | | 0 | 1 | 1 |
| ២-ឥណទានក្រុមជានា | | | | | | | | |
| ខ | កំពង់ធំ | 7,100,000 | 3 | 11 | | 11 | 2 | 1 |
| សរុប | | 7,100,000 | 3 | 11 | | 11 | 2 | 1 |
| សរុបរួម | | **19,100,000** | 4 | 12 | | 12 | 2 | 1 |

**៥.៦. អង្គការអភិវឌ្ឍន៍កុមារតូច (RTI)**

- ចុះធ្វើការសម្របសម្រួលស្តីពី ការអប់រំអ្នកថែទាំកុមារតូច នៅស្រុកសណ្តាន់ ចំនួន០២លើក អ្នកចូលរួមសរុប ៧៨នាក់ ស្រី៤៩នាក់
- ចូលរួមទិវាអាហាររូបត្ថម្ភ នៅឃុំងន ស្រុកសណ្តាន់ ដែលគាំទ្រដោយអង្គការ RTI និងអង្គការ Helen Keller។

## ៥.៧. អង្គការទស្សនៈពិភពលោក

- ចុះវាយតម្លៃ និងផ្ទៀងផ្ទាត់ភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (ODF) នៅភូមិខ្សាច់ដីរស់ ឃុំកំពង់គោ ស្រុកកំពង់ស្វាយ
- ចូលរួមសម្របសម្រួល វាយតម្លៃភូមិបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ចំនួន ០២ លើក នៅឃុំកំពង់គោលើ ស្រុកកំពង់ស្វាយ និងឃុំប្រាសាទ ស្រុកសន្ទុក
- ចូលរួមវាយតម្លៃ និងផ្ទៀងផ្ទាត់ឃុំបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល (ODF) ចំនួន ០១ឃុំ គឺឃុំប្រាសាទ ស្រុកសន្ទុក ដើម្បីត្រៀមរៀបចំកម្មវិធីអបអរឃុំបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល(ODF)
- ចុះវាយតម្លៃ និងផ្ទៀងផ្ទាត់ភូមិបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល (ODF)បានចំនួន ០៤ភូមិៈភូមិតាអាំ អូរអំបែង ស្រង៉ែ ពោធិ៍ ឃុំត្បែង ស្រុកកំពង់ស្វាយ ជាលទ្ធផលភូមិទាំង ០៤បានជាប់ជាភូមិODF
- ចុះទស្សនកិច្ចសិក្សា និងផ្តល់យោបល់ អំពីស្ថានភាពទឹកស្អាត និងអនាម័យទៅតាមសាលាបឋមសិក្សា និងភូមិគោលដៅ ក្នុងឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ
- ចុះសម្របសម្រួល ស្តីពីកិច្ចប្រជុំផ្សព្វផ្សាយ និងជំរុញសហគមន៍ នៅឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ
- ចុះសម្របសម្រួលការវាយតម្លៃភូមិ ODF នៅឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ
- ផ្តល់វគ្គបណ្តុះបណ្តាលរយៈពេល៥ថ្ងៃស្តីពី ការងារលើកកម្ពស់អនាម័យជនបទ នៅឃុំតាំងក្រសាំង ស្រុកសន្ទុក
- ចូលរួមវគ្គសិក្ខាសាលាស្តីពី សហគមន៍ទទួលបានចំនេះដឹងលើការប្រើប្រាស់ទឹកស្អាត និងហូបទឹកសុវត្ថិភាព ដោយប្រើប្រាស់វិធីសាស្ត្រធ្វើទីផ្សារបន្សុតទឹក តាមបទដ្ឋានបច្ចេកទេសផ្តោតលើការធ្វើតេស្តរកសារធាតុ អាសុីត, PH, អាល់កាឡាំង, ក្លរ និងភាពល្អក់ ដើម្បីសហគមន៍ទទួលបានសុខភាពល្អ
- ចូលរួមសកម្មភាព សហគមន៍ដឹកនាំអនុវត្តអនាម័យ(CLTS)ចំនួន០៣ភូមិគឺៈ ភូមិកំពង់គោលើ, កំពង់គោក្រោម និងបូពឹង ឃុំកំពង់គោ ស្រុកកំពង់ស្វាយ
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់វាយតម្លៃភូមិ ODF នៅឃុំកំពង់ថ្ម និងឃុំប្រាសាទ ស្រុកសន្ទុក ចំនួន០៤ភូមិ។

## ៥.៨. អង្គការអភិវឌ្ឍន៍ជំនាញទឹកស្អាត និងអនាម័យ

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីៈ ទឹកស្អាត ការសំអាត និងអនាម័យប្រកបដោយបរិយាបន្ន នៅសណ្ឋាគារជំរីជាន់ខ្លា ខេត្តកំពង់ធំ។

## ៥.៩. អង្គការស្អាតកម្ពុជា

| ល.រ | សកម្មភាព | បរិមាណ | ទីតាំង | | | លទ្ធផលទទួលបាន (outputs) |
|---|---|---|---|---|---|---|
| ផ្នែកចម្រោះទឹកគ្រួសារ | | | ឃុំ | ស្រុក | ខេត្ត | |
| ១ | សាងសង់ចម្រោះជូនប្រជាពលរដ្ឋ | 784 ចម្រោះ | ប្រាសាទសំបូ, តាំងក្រសៅ,ជ័យ | ប្រាសាទសំបូរ | កំពង់ធំ | ១០០% |
| ២ | តម្លើងចម្រោះអោយប្រជាពលរដ្ឋបានប្រើប្រាស់ | 784 ចម្រោះ | ប្រាសាទសំបូ, តាំងក្រសៅ,ជ័យ | ប្រាសាទសំបូរ | កំពង់ធំ | |
| ៣ | ត្រួតពិនិត្យចម្រោះដែលមានអាយុពី ១ខែ ៣ខែ និង ១ឆ្នាំ | 1111 ចម្រោះ | ប្រាសាទសំបូ, តាំងក្រសៅ,ជ័យ | ប្រាសាទសំបូរ | កំពង់ធំ | |
| វគ្គបណ្តុះបណ្តាលនិងការអប់រំសុខភាព | | | | | | |
| ៤ | បង្រៀនពីរបៀបសាងសង់និងដំឡើងចម្រោះទឹកដល់អ្នកស្មគ្រ័ចិត្តភូមិ | 144 នាក់ | ប្រាសាទសំបូ, តាំងក្រសៅ,ជ័យ | ប្រាសាទសំបូរ | កំពង់ធំ | |
| ៥ | ផ្សព្វផ្សាយពីចម្រោះទឹកនិងផលប៉ះពាល់បណ្តាលមកពីការប្រើប្រាស់ទឹកមិនស្អាត | 985 នាក់ | ប្រាសាទសំបូ, តាំងក្រសៅ,ជ័យ | ប្រាសាទសំបូរ | កំពង់ធំ | |
| ៦ | វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការធ្វើផែនការផ្លូវចម្លងរោគ | 114 នាក់ | ប្រាសាទសំបូ, តាំងក្រសៅ,ជ័យ | ប្រាសាទសំបូរ | កំពង់ធំ | |
| ៧ | គ្រូបង្គោលប្រជុំផ្សព្វផ្សាយពីទឹកសុវត្ថភាពនិងផ្លូវចម្លងរោគ | 985 នាក់ | ប្រាសាទសំបូ, តាំងក្រសៅ,ជ័យ | ប្រាសាទសំបូរ | កំពង់ធំ | |
| ៨ | ប្រជុំអប់រំសុខភាព( ទុកដាក់ទឹកមានសុវត្ថភាព លាងដៃជាមួយសាប៊ូ | 1130 នាក់ | ប្រាសាទសំបូ, តាំងក្រសៅ,ជ័យ | ប្រាសាទសំបូរ | កំពង់ធំ | |
| ផ្នែកចម្រោះទឹកសាលារៀន | | | | | | |
| ៩ | សាងសង់ចម្រោះសាលារៀន និងតម្លើងចម្រោះ | 30 ចម្រោះ | | ប្រាសាទសំបូរ, សន្ទុក ,បារាយណ៍ | កំពង់ធំ | |
| ១០ | សាងសង់បង្គន់អនាម័យ | 19 សាលា | | ប្រាសាទសំបូរ, សន្ទុក ,បារាយណ៍ | កំពង់ធំ | |
| ១១ | សាងសង់ឡដុតសម្រាម | 19 សាលា | | ប្រាសាទសំបូរ, សន្ទុក ,បារាយណ៍ | កំពង់ធំ | |
| ១២ | សាងសង់កន្លែងលាងដៃ | 19 សាលា | | ប្រាសាទសំបូរ, សន្ទុក ,បារាយណ៍ | កំពង់ធំ | |
| វគ្គបណ្តុះបណ្តាលស្តីពីការលាងសំអាតដៃជាមួយសាប៊ូ | | | | | | |
| ១៣ | បុគ្គលិកបង្រៀនអំពីមេរៀនការលាងសម្អាតដៃជាមួយសាប៊ូទៅនាយក នាយិកា និង ការិយាល័យ | 8040 នាក់ | | ប្រាសាទសំបូរ, សន្ទុក ,បារាយណ៍ | កំពង់ធំ | |
| ១៤ | បន្តពីនាយក នាយិកាទៅគ្រូអំពីមេរៀនការលាងសម្អាតដៃជាមួយសាប៊ូ | ២៧៤ | | ប្រាសាទសំបូរ, សន្ទុក ,បារាយណ៍ | កំពង់ធំ | |

## II. បញ្ហាប្រឈម និងសំណូមពរ

- បញ្ហាប្រឈម
  - សមត្ថភាព និងបទពិសោធន៍មន្ត្រីមួយចំនួននៅមានកម្រិត
  - គណៈកម្មការថែទាំអណ្តូងពុំសូវដំណើរការ

- អ្នកភូមិភាគច្រើនចង់បានអណ្តូងទឹកគ្រប់ផ្ទះ
- លំបាកក្នុងការប្រមូលសហគមន៍មកចូលរួមប្រជុំ
- ផ្លូវជនបទរងគ្រោះដោយសាររថយន្តដឹកជញ្ជូនផ្ទុកលើសទំងន់
- អាជ្ញាធរមូលដ្ឋានពុំសូវជំរុញគណៈកម្មការ (CBOs) អោយដំណើរការកិច្ចការអភិវឌ្ឍន៍
- វិបាកក្នុងការកែទម្លាប់របស់សហគមន៍
- ខេត្តរងគ្រោះដោយទឹកជំនន់ជារៀងរាល់ឆ្នាំ
- ផ្លូវជនបទទទួលរងការខូចខាតដោយទឹកជំនន់ជាច្រើនខ្សែតែ ថវិកាមិនមានគ្រប់គ្រាន់
- ការអនុវត្តកម្មវិធីលទ្ធកម្មមានការយឺតយ៉ាវ
- គ្មានថវិកាជួសជុល ថែទាំប្រចាំផ្លូវក្រាលកៅស៊ូដែលមានស្រាប់។

- សំណូមពរ
  - ស្នើសុំឲ្យមានការបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែង ដល់មន្ត្រី
  - ស្នើឲ្យមានទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស
  - ស្នើឲ្យមានការបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីជម្រុញលើការងារទឹកស្អាត និងអនាម័យនៅតាមតំបន់រងគ្រោះដោយសារជាតុអាសេនិច (សាងសង់ប្រព័ន្ធចែកចាយទឹកខ្នាតតូច)
  - សុំឲ្យដៃគូអភិវឌ្ឍន៍នានា និងអាជ្ញាធរពាក់ព័ន្ធជួយសហការលើការងារសុខភាពអនាម័យ (បង្គន់អនាម័យ)
  - សុំឲ្យមានការសិក្សាបន្ថែម នូវផ្លូវជនបទណាដែលបង្កភាពងាយរងគ្រោះដោយទឹកជំនន់ ដូចជា ការបន្ថែមលូដោះទឹក ឬក៏សាងសង់ជាស្ពានជាដើម
  - អាជ្ញាធរមូលដ្ឋានជួយសម្រួល ក្នុងការប្រមូលសហគមន៍ចូលរួមប្រជុំ
  - អាជ្ញាធរមូលដ្ឋានត្រូវមានវិធានការទប់ស្កាត់ លើការដឹកលើសទំងន់លើផ្លូវជនបទ
  - អាជ្ញាធរមូលដ្ឋានគួរជំរុញគណៈកម្មការ (CBOs) ឲ្យដំណើរការរាល់កិច្ចការអភិវឌ្ឍន៍
  - អាជ្ញាធរមូលដ្ឋានគួរជំរុញអោយប្រជាពលរដ្ឋចូលរួមសាងសង់បង្គន់ និងប្រើប្រាស់បង្គន់ជាប់ជាប្រចាំ
  - ស្នើសុំថវិកាទៅតាមផែនការសម្រាប់ឆ្នាំ ២០២៣ ឲ្យបានទាន់ពេលវេលា
  - ស្នើសុំថវិកាសម្រាប់ជួសជុល ថែទាំផ្លូវក្រាលកៅស៊ូ (លក្ខណៈប្រចាំ)
  - ស្នើសុំថវិកាត្រៀមបម្រុងសម្រាប់ជួសជុល កែលម្អអណ្តូងទឹកដែលរីងស្ងួត។

## III. ទិសដៅការងារឆ្នាំ ២០២៣

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

- ការកសាងផែនការអភិវឌ្ឍន៍ជនបទ សម្រាប់ខេត្តកំពង់ធំ
- ការពង្រឹងសវនកម្មផ្ទៃក្នុង ពិសេសការងារ M&E
- ការកសាងសមត្ថភាពមន្ត្រីថ្នាក់មន្ទីរ
- បន្តការបណ្តុះបណ្តាលសហគមន៍ជនបទ
- ពង្រឹងការមកបំពេញការងារប្រចាំថ្ងៃរបស់មន្ត្រីរាជការ (បញ្ជីវត្តមានប្រចាំថ្ងៃ)។

**២.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

- ធ្វើការជួសជុលផ្លូវក្រាលគ្រួសក្រហម ០១ខ្សែ ទទឹង ៤.៥ គម ស្ថិតក្នុងស្រុកបារាយណ៍
- ចុះស្រង់ទិន្នន័យខ្សែផ្លូវដើម្បីប្រមូលព័ត៌មាន និងគ្រប់គ្រងទិន្នន័យផ្លូវជនបទទាំងអស់ ២២ ខ្សែ ប្រវែង ៤០គម
- ចុះធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌផ្លូវជនបទ ក្រុង ដើម្បីគ្រប់គ្រងទិន្នន័យផ្លូវជនបទទាំងអស់ ៣៥ ខ្សែ ប្រវែង ៣៥០គម
- ចុះធ្វើការរាប់ចំនួនចរាចរណ៍យានយន្ត លើផ្លូវចំនួន ០៨ ខ្សែ ស្ថិតក្នុងស្រុកស្ទោង ស្រុកប្រាសាទបល្ល័ង្គ ស្រុកសន្ទុក ស្រុកបារាយណ៍ស្រុកតាំងគោក ស្រុកប្រាសាទ សំបូរ ស្រុកសណ្តាន់ និងស្រុកកំពង់ស្វាយ
- ធ្វើការដាំកូនឈើគ្រប់ប្រភេទតាមផ្លូវជនបទ ចំនួន ៥៤០ ដើម និងគ្រាប់ត្នោតចំនួន ៨០០ គ្រាប់ នៅស្រុកស្ទោង
- សាងសង់ទីទួលសុវត្ថិភាពចំនួន ០១កន្លែង ស្ថិតក្នុងសង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន។

**៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

- ការងារថែទាំសុខភាពជនបទ
  - ចុះអប់រំផ្សព្វផ្សាយ និងអប់រំសហគមន៍ពីលក្ខខ័ណ្ឌនៃការរស់នៅស្អាត ចំនួន ០៨វគ្គ នៅ ០៦ស្រុក
  - បង្កើនសហគមន៍បញ្ឈប់បន្ទោរបង់ពាសវាលពាសកាល (ODF) ចំនួន ១៨វគ្គ នៅ ០៦ស្រុក
  - ការសាងសង់បង្គន់អនាម័យ/បដិភាគសម្ភារៈអនាម័យ ចំនួន ១៨បង្គន់ នៅស្រុកប្រាសាទសំបូរ
  - រៀបចំកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំរបស់ក្រុមការងារPWG ថ្នាក់ខេត្ត ប្រចាំត្រីមាស
  - រៀបចំបង្កើតក្រុមការងារបច្ចេកទេសទឹកស្អាត និងអនាម័យជនបទ(DWGs) ថ្នាក់ស្រុក
  - រៀបចំផែនការឃុំ-ស្រុក ODF។
- ការងារផ្គត់ផ្គង់ទឹកជនបទ
  - បន្តចុះត្រួតពិនិត្យស្ថានីយបន្សុទ្ធទឹកសហគមន៍ តាមស្រុកគោលដៅ
  - ចុះអប់រំផ្សព្វផ្សាយ ការប្រើប្រាស់ទឹកស្អាតប្រកបដោយសុវត្ថិភាព ចំនួន ២៥ វគ្គ នៅ ០៥ស្រុក
  - លើកគម្រោងផែនការសកម្មភាព សាងសង់អណ្តូងស្នប់ជ្រៅថ្មី សម្រាប់ឆ្នាំ ២០២៣។

**៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- ចុះសិក្សាប៉ាន់ប្រមាណតម្រូវការវិជ្ជាជីវៈដល់សហគមន៍ និងក្រុមប្រឹក្សា ចំនួន ១៣លើក ស្មើនឹង ១៣ឃុំ ៤ស្រុក ស្រុកតាំងគោក ស្រុកស្ទោង ស្រុកសណ្តាន់ និងប្រាសាទបល្ល័ង្គ
- ផ្សព្វផ្សាយទិវាជនជាតិដើមភាគតិចប្រចាំឆ្នាំ ចំនួន ០១លើក
- បណ្តុះបណ្តាល គ.អ.ភ ចំនួន ០៥វគ្គ និងចុះធ្វើបច្ចុប្បន្នភាព គ.អ.ភ ចំនួន ០៨លើក ស្មើនឹង ១៣ឃុំ ០២ស្រុក
- ចុះតាមដានសហគមន៍ឥណទានចំនួន ១២វគ្គ ១២ឃុំ ០៣ស្រុក ស្រុកស្ទោង, ប្រាសាទបល្ល័ង្គ, សណ្តាន់។

**សេចក្តីសន្និដ្ឋាន**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំបានខិតខំអនុវត្តនូវតួនាទីរបស់ខ្លួនយ៉ាងសកម្មដោយសម្រេចបាននូវសមិទ្ធផលការងារជាច្រើន ដើម្បីរួមចំណែកបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទឲ្យកាន់តែរីកចម្រើន និងជួយឲ្យសុខុមាលភាពរបស់ពួកគាត់កាន់តែប្រសើរឡើងថែមទៀត ព្រមទាំងរួមចំណែកអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំដោយគតិបណ្ឌិត។